ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សូមក្រាបថ្វាយបង្គំចំពោះ**
**គណៈសង្ឃវត្តបាលិលេយ្យ និងនៅក្នុងប្រទេសសហរដ្ឋអាមេរិកគ្រប់អង្គ**

***ព្រះតេជគុណគ្រប់អង្គជាទីគោរពសក្ការ !***

ខ្ញុំព្រះករុណា **ភិក្ខុអ៊ឹម.ឧត្តម "អគ្គធរោ"** គង់នៅវត្តបាសាលវ៉ែន និងជាសមណនិស្សិតខ្មែរកំពុងសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកព្រះពុទ្ធសាសនា ក្នុងខេត្តនគររាជសីមា ប្រទេសថឡង់ដឺ ។ សូមសំដែងនូវសេចក្តីដ៏សោកស្តាយយ៉ាងខ្លាំង ចំពោះការបាត់បង់នូវសម្តេចព្រះសង្ឃរាជ សម្តេចព្រះមហាឃោសនន្ទ "សម្តេចយ៉ាវ" ដែលជាព្រះមហាវិរៈសង្ឃនៃប្រទេសកម្ពុជារបស់ពុទ្ធបរិស័ទខ្មែរ និងក៏ដូចជាលើពិភពលោកទាំងមូលគ្រប់រូបផងដែរ ។ ដែលព្រះអង្គទ្រង់បានទទួលព្រះសុគត កាលពី ថ្ងៃទី ១២ មិនា ២០០៧ កន្លងទៅអស់រយះពេល ៣ ឆ្នាំមកនេះ ។ និងបានប្រារព្ធធ្វើពិធិបុណ្យខួប គម្រប់ ៣ ឆ្នាំ នៅថ្ងៃទី ២១-២២ មិនា ២០១០ ដើម្បីឧទ្ទិសថ្វាយដល់ព្រះវិញ្ញាណខន្ធរបស់ព្រះអង្គនេះ ។ សូមសម្តែងនូវការសោកស្តាយនិងសូមចូលរួមនៅការចែករំលែកការសោកស្តាយ ជាមួយគណៈសង្ឃ និង ពុទ្ធបរិស័ទ្យ វត្តបាលិលេយ្យក្នុង សហរដ្ឋអាមេរិក ក៏ដូចជានៅក្នុងប្រទេសកម្ពុជាទាំងមូលផងដែរ ។

ក្នុងឧកាសនេះ ខ្ញុំព្រះករុណាសូមចូលរួមអនុមោទនានូវបុណ្យកុសលនេះនិងដើម្បីឧទ្ទិសប្រគេន ថ្វាយដល់ព្រះវិញ្ញាណខន្ធចំពោះសម្តេចព្រះមហាឃោសនន្ទ សូមឱ្យព្រះវិញ្ញាណខន្ធរបស់ព្រះអង្គបានទទួល និង បង្កើតក្នុងសុគតិភពជាស្ថានទីដ៏ខ្ពង់ខ្ពស់កុំបីអាក់ខានឡើយ ។

សូមទទួលនូវការគារវះដ៏ខ្ពង់ខ្ពស់អំពីខ្ញុំព្រះករុណា ។

សេចក្តីគួរពុំគួរសូមអត់ទោសដោយមេត្តាធមិ ។

ប្រទេសថៃ. ថ្ងៃទី ១៨ មិនា ២០១០

**ភិក្ខុអ៊ឹម.ឧត្តម "អគ្គធរោ"**

វត្តបាសាលវ៉ែន នគររាជសីមា
udom1984_student@hotmail.com
Tel: (66) 83-3766892